00710373

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 24 / 06 / 2011
ម៉ោង (Time/Heure) : 09:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**លេខ/No: A410/2/6**

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១៤៧)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១១

---

**សាធារណៈ**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេត**
**ទៅនឹងសំណើស្តីពីការរក្សាការសម្ងាត់ សមភាព និង ភាពយុត្តិធម៌**

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Andrew CAYLEY

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

សំ សុគង់
Lyma Thuy NGUYEN
ហុង គឹមសួន
Pascal AUBOIN

**<u>ជនជាប់ចោទ</u>**

អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន
នួន ជា

00710374

ពេជ អង្គ
ជេត វណ្ណលី
វ៉ែន ពៅ
ឡោ ជុនធី
Olivier BAHOUGNE
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Christine MARTINEAU
Elizabeth RABESANRATANA
Philippe CANONNE
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
គង់ ពិសី
យុង ផានិត
ស៊ីន សុវន
Silke STUDZINSKY
Mahdev MOHAN
Patrick BAUDOIN
Marie GUIRAUD
ទី ស្រ៊ីនណា
Ferdinand DJAMMEN-NZEPA
Isabelle DURAND
Emmanuel ALTIT
Emmanuel JACOMY
Barnabe NEKUIE
Daniel LOSQ
Julien RIVET
Francoise GAUTRY
Laure DESFORGES

<u>**សហមេធាវីការពារក្តីជនជាប់ចោទ**</u>

**អៀង សារី**
អាង ឧត្តម
Michael G. KARNAVAS

**អៀង ធីរិទ្ធ**
Diana ELLIS
ផាត់ ពៅស៊ាង

**ខៀវ សំផន**
Jacques VERGES
ស សូវ៉ាន

**នួន ជា**
Victor KOPPE
Michiel PESTMAN
សុន អារុណ

E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេត ទៅនឹងសំណើស្តីពីការរក្សាការសម្ងាត់ សមភាព និង ភាពយុត្តិធម៌” ដែលបានដាក់ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (“សហមេធាវី”) កាលពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១០ និងបានជូនដំណឹងនៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០ (“បណ្តឹងឧទ្ធរណ៍”)[១]។

## I. ប្រវត្តិនីតិវិធី និងការដាក់ឯកសារនានា

១. នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០ សហមេធាវីបានដាក់សំណើមួយស្តីពីការរក្សាការសម្ងាត់ សមភាព និង យុត្តិធម៌ ជូនទៅសហចៅក្រមស៊ើបអង្កេត (“សំណើរបស់សហមេធាវី”) ដោយបានអះអាងថា សេចក្តីសម្រេចរបស់ការិយាល័យរដ្ឋបាលនៅដើមខែ កក្កដា ឆ្នាំ ២០១០ ដែលបានផ្លាស់ពួកគេចេញពីអាគារតុលាការ ឱ្យទៅអង្គុយធ្វើការរួមគ្នានៅការិយាល័យតុលាការនៅក្នុងក្រុងភ្នំពេញ បានធ្វើឱ្យប៉ះពាល់ដល់លក្ខខណ្ឌធ្វើការងាររបស់ខ្លួន (ការចូលប្រើ Zylab យឺតយ៉ាវ ការលំបាកក្នុងការបំពេញការងារតាមកាលបរិច្ឆេទកំណត់ដែលមានរយៈពេលខ្លី បន្ទប់ការិយាល័យសម្រាប់ធ្វើការ និងសម្ភារៈបរិក្ខារមិនគ្រប់គ្រាន់) និងធ្វើឱ្យមានការលំបាកក្នុងការធានាឱ្យបានថាការងាររបស់ពួកគេរក្សាបាននូវការសម្ងាត់។ សហមេធាវីបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចាត់វិធានការចាំបាច់ ដើម្បីកែលំអលក្ខខណ្ឌការងាររបស់ពួកគេ ក្នុងគោលបំណងរក្សាបាននូវភាពសម្ងាត់ចំពោះព័ត៌មាន និងធានានូវការប្រព្រឹត្តយ៉ាងមានសមភាពជាមួយភាគីដទៃទៀត[២]។

២. នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបតាមរយៈលិខិតមួយច្បាប់ទៅនឹងសំណើរបស់សហមេធាវី ដោយបានអះអាងថា ពួកគាត់ពុំមានយុត្តាធិការទៅលើបញ្ហានោះ

[១] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើស្តីពីការរក្សាការសម្ងាត់ សមភាព និង យុត្តិធម៌ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១០ ឯកសារលេខ A410/2/1 (“បណ្តឹងឧទ្ធរណ៍”)។

[២] សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីការរក្សាការសម្ងាត់ សមភាព និង យុត្តិធម៌ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០ ឯកសារលេខ A410។

ទេ ហើយបានបញ្ជូនរឿងនោះទៅជូនប្រធាន និង អនុប្រធានការិយាល័យរដ្ឋបាល ដើម្បីបំពេញការងារនេះវិញ (“ចម្លើយរបស់សហចៅក្រមស៊ើបអង្កេត”)[៣]។

៣. សហមេធាវីបានដាក់លិខិតជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០[៤] ហើយពួកគេបានដាក់បណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១០។ តាមរយៈបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីបានលើកជាទឡ្ហីករណ៍ថា ដូចដែលបានលើកឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតរួចមកហើយគឺថា លក្ខខណ្ឌការងាររបស់គាត់ ធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពក្នុងការរក្សាការសម្ងាត់ផង និងលទ្ធភាពក្នុងការធ្វើជាតំណាងយ៉ាងមានប្រសិទ្ធភាពដល់កូនក្តីរបស់ខ្លួន និងសិទ្ធិនៃការចូលរួមយ៉ាងមានសមភាព ដែលពួកគេមានសិទ្ធិទទួលបាន[៥]។ សហមេធាវីបានលើកឡើងថា ដោយសារវិធាន២១ តម្រូវឱ្យ អ.វ.ត.ក ធានានូវសិទ្ធិរបស់ជនរងគ្រោះ តែមិនបានបញ្ជាក់ឱ្យបន្ថែមថាតើអង្គភាពណាមួយជាអ្នកធានានូវសិទ្ធិទាំងនេះ នោះយើងត្រូវបកស្រាយថា អង្គភាពទាំងអស់ជាអ្នកត្រូវបំពេញកិច្ចការនេះ។ ដោយសារការិយាល័យរដ្ឋបាលបានដឹងពីបញ្ហានេះហើយ តែមិនមានលទ្ធផលអ្វីគួរឱ្យកត់សម្គាល់នោះ សហមេធាវីក៏បានងាកទៅរកសហចៅក្រមស៊ើបអង្កេត ដោយសារអង្គភាពនេះពាក់ព័ន្ធក្នុងការដោះស្រាយសំណើនានានៅដំណាក់កាលមុនសវនាការ។ ពួកគេបានលើកឡើងជាទឡ្ហីករណ៍ថា ការណ៍ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធមិនទទួលយកសំណើនេះ សហចៅក្រមស៊ើបអង្កេតបានរំលោភទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដូចដែលមានចែងនៅក្នុងមាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”) វិធាន ២១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) និងគោលការណ៍មូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានរួមលើច្បាប់

---

[៣] លិខិតពីសហចៅក្រមស៊ើបអង្កេតផ្ញើជូនសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានចំណងជើងថា “ពាក្យសុំទាក់ទិននឹងការរក្សាការសម្ងាត់ សមភាព និង យុត្តិធម៌ របស់លោក-លោកស្រីមេធាវី ចុះថ្ងៃទី ៣១ ខែ សីហា បានដាក់នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ A410/1។

[៤] លិខិតជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ ឯកសារ A410/2។

[៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧-២១។

សិទ្ធិមនុស្សអន្តរជាតិ[៦] [៧]។ ពួកគេបានស្នើសុំអង្គបុរេជំនុំជម្រះឱ្យ “សម្រេចទៅលើសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយចាត់វិធានការចាំបាច់ដើម្បីរៀបចំលក្ខខណ្ឌធ្វើការងាររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឱ្យបានប្រហាក់ប្រហែលនឹងលក្ខខណ្ឌធ្វើការងារនៅតុលាការនេះ ដោយត្រូវធានាមិនឱ្យបញ្ចេញឯកសារសម្ងាត់ (បំផុត) និងរៀបចំលក្ខខណ្ឌធ្វើការងារឱ្យបានស្មើគ្នានឹងលក្ខខណ្ឌធ្វើការងាររបស់ភាគីដទៃទៀត”[៨]។

៤. ការិយាល័យរដ្ឋបាលបានដាក់ “ចម្លើយតបទៅលើ “សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០” និង “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១០”” នៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១០[៩] (“ចម្លើយតបរបស់ការិយាល័យរដ្ឋបាលទៅលើបណ្តឹងឧទ្ធរណ៍”) ដោយក្នុងនោះការិយាល័យនេះបានលើកឡើងថា ១)ការអនុវត្តតួនាទីរបស់ការិយាល័យនេះមានកម្រិតដោយសារកង្វះធនធាន ២)សហមេធាវីទាំងពីររូបដែលបានដាក់សំណើខកខានមិនបានបង្កើតឱ្យមានលំនៅវិជ្ជាជីវៈមួយនៅប្រទេសកម្ពុជា ដែលជាការរំលោភបំពានដល់ក្រមសីលធម៌របស់គណៈមេធាវីកម្ពុជា ៣)សហមេធាវីទទួលខុសត្រូវក្នុងការធានានូវការបំពេញភារកិច្ចរបស់ខ្លួនដើម្បីរក្សាការសម្ងាត់តាមមាត្រា៧ នៃក្រមសីលធម៌ និង ៤)ក្រុមអ្នកច្បាប់ដែលបានដាក់បណ្តឹងឧទ្ធរណ៍ បានរំលោភបំពានលើមាត្រា២៥ នៃក្រមសីលធម៌ ដោយបានពិគ្រោះយោបល់ជាមួយកូនក្តីរបស់មេធាវីដទៃ ដោយមិនបានទទួលការអនុញ្ញាតជាមុន។

---

[៦] មហាសន្និបាតអង្គការសហប្រជាជាតិ, គោលការណ៍មូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានរួមលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ឯកសារលេខ A/Res/60/147 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦។

[៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១២-១៣។

[៨] បណ្តឹងឧទ្ធរណ៍ ទំព័រ៩។

[៩] “ចម្លើយតបទៅនឹង “សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០” និង “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១០”” ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ A140/2/2។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

៥. បន្ទាប់ពីអង្គបុរេជំនុំជម្រះធ្វើការអញ្ជើញ ហើយបន្ទាប់ពីអង្គជំនុំជម្រះបានសម្រេចថានឹងធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកទៅលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ[១០] ទើបសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមាននិយាយយោងជាពិសេសនៅក្នុងចម្លើយតបរបស់ការិយាល័យរដ្ឋបាល ដែលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ បានដាក់សារណាតបក្នុងនាមខ្លួនឯងផ្ទាល់ ដោយលើកឡើងជាសំខាន់ថា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានរំលោភទៅលើកាតព្វកិច្ចណាមួយរបស់ខ្លួន តាមក្រមសីលធម៌នោះឡើយ[១១]។

## II. ការទទួលយកបណ្តឹងឧទ្ធរណ៍

៦. អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍បានដាក់តាមកាលបរិច្ឆេទរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេត បានចេញនូវចម្លើយរបស់ខ្លួន ដោយសារតែថ្ងៃទី ៨ និងថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១០ គឺជាថ្ងៃឈប់សម្រាកជាផ្លូវការ។

៧. សហមេធាវីបានលើកឡើងថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបានដោយផ្អែកទៅលើ វិធាន ២១ (១)(ក) និង(គ) នៃវិធានផ្ទៃក្នុង ហើយបានលើកឡើងទៀតថា នៅពេលកន្លងមក អង្គបុរេជំនុំជម្រះបានអនុម័តយកការបកស្រាយទូលំទូលាយទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការប្តឹងឧទ្ធរណ៍ ហើយបានសង្កត់ធ្ងន់ទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី/អ្នកដាក់ពាក្យសុំ ក្នុងការទទួលបានការជំនុំជម្រះ និងទទួលបាននូវភាពយុត្តិធម៌ក្នុងដំណើរការនីតិវិធី[១២]។

៨. វិធាន ២១ នៃវិធានផ្ទៃក្នុងចែងត្រង់ចំណុចពាក់ព័ន្ធថា៖

"១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តី

[១០] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ A410/2/3។

[១១] សារណាតបទៅនឹងចម្លើយរបស់ការិយាល័យរដ្ឋបាល ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ A410/2/4 និងការឆ្លើយតបទៅនឹងចម្លើយតបរបស់ការិយាល័យរដ្ឋបាល ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ A410/2/5។

[១២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥ ដល់ ៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00710379



ណែនាំអនុវត្ត និងបទបញ្ញារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក-ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ។ នីតិវិធីត្រូវធានាឱ្យបាននូវភាពដាច់ ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និង អាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។

[...]

គ-អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថាជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី។

៩. អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ដោយអនុលោមទៅតាមវិធាន៧៤នៃវិធានផ្ទៃក្នុង ភាគីទាំងអស់មិនមែនមានសិទ្ធិប្តឹងឧទ្ធរណ៍ទៅលើរាល់ដីកាសម្រេចទាំងអស់របស់សហចៅក្រមស៊ើបអង្កេតនោះទេ ហើយថា ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ប្រឆាំងតែទៅនឹងដីកាសម្រេច ឬសេចក្តីសម្រេចទាំងឡាយដូចមានចែងក្នុងវិធាន ៧៤(៤) តែប៉ុណ្ណោះ។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលត្រូវបានប្តឹងឧទ្ធរណ៍ ក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះ មិនស្ថិតនៅក្នុងចំណោមសេចក្តីសម្រេច ឬដីកាសម្រេចដែលដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍បាននោះឡើយ។

១០. បន្ថែមពីលើនេះទៀត វិធាន ២១ ដែលខុសពីវិធាន ៧៤ មិនបានផ្តល់មូលដ្ឋានសម្រាប់ការប្តឹងឧទ្ធរណ៍នៅដំណាក់កាលមុនអង្គជំនុំជម្រះនោះឡើយ ប៉ុន្តែវិធាននេះបានបង្ហាញនូវគោលការណ៍ជាសារវន្តសម្រាប់គ្រប់គ្រងលើដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក[១៣]។ បើទោះបីជាអង្គបុរេជំនុំជម្រះយល់ឃើញថា ដោយសារតែអង្គហេតុ និងកាលៈទេសៈនៃបណ្តឹងឧទ្ធរណ៍តម្រូវ ខ្លួនមានសមត្ថកិច្ចក្នុងការពិចារណាលើមូលដ្ឋានដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើង ដែលមូលដ្ឋាន

[១៣] សូមមើលផងដែរ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ D427/2/15 កថាខណ្ឌ ៧០។

នេះមិនមានចែងច្បាស់លាស់នៅក្នុងវិធាន ៧៤ តាមរយៈការបកស្រាយដោយសេរីទៅលើសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ដោយផ្អែកទៅតាមវិធាន២១ នៃវិធានផ្ទៃក្នុងក៏ដោយ ក៏វាមិនអាចចាត់ទុកថាជាវិធានទូទៅដែលថាអង្គបុរេជំនុំជម្រះមានសមត្ថកិច្ចជាស្វ័យប្រវត្តិតាមវិធាន ២១ ក្នុងការពិចារណាទៅលើមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងនូវបញ្ហាដែលពាក់ព័ន្ធទៅនឹងភាពយុត្តិធម៌នៃដំណើរការនីតិវិធី[១៤]។ ផ្ទុយទៅវិញ ការប្រើប្រាស់វិធាន ២១ នៃវិធានផ្ទៃក្នុងដើម្បីប្រកាសថាបណ្តឹងឧទ្ធរណ៍មួយអាចទទួលយកបាននោះ គឺជាករណីលើកលែង ហើយអនុវត្តបានតែក្នុងករណីដែលអង្គហេតុ និងកាលៈទេសៈជាក់លាក់តម្រូវឲ្យមានការបកស្រាយដោយទូលំទូលាយទៅលើសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ[១៥]។

១១. ក្នុងសំណុំរឿងបច្ចុប្បន្ននេះ សហមេធាវីមិនបានធ្វើឲ្យអង្គបុរេជំនុំជម្រះជឿជាក់ថា សហមេធាវីត្រូវទទួលរងការរារាំងពីការធានាបាននូវសិទ្ធិទទួលការជំនុំជម្រះប្រកបដោយយុត្តិធម៌សម្រាប់កូនក្តីរបស់ខ្លួន ក្នុងដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីនោះឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ថា សេចក្តីសម្រេចធ្វើការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់សហមេធាវីទៅការិយាល័យនៅទីក្រុងភ្នំពេញ ដែលនេះជាមូលដ្ឋាននៃដំណើរការនីតិវិធីក្នុងពេលបច្ចុប្បន្ននេះ ត្រូវបានសម្រេចកាលពី "ដើមខែកក្កដា ឆ្នាំ ២០១០" គឺបន្ទាប់ពីបញ្ចប់កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០២ និងនៅមុនពេលសហមេធាវីបានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់កូនក្តីខ្លួន តែបន្តិចប៉ុណ្ណោះ ដែលការចេញដីកាសម្រេចនេះ គឺជាការងារចុងក្រោយរបស់សហចៅក្រមស៊ើបអង្កេត មុនពេលដែលសំណុំរឿង ០០២ ត្រូវបានលើកយកមកជំនុំជម្រះ។ ដោយសារតែអង្គបុរេជំនុំជម្រះបានទទួលស្គាល់ពីការលំបាកមួយចំនួន ដែលសហមេធាវីបានជួបប្រទះ ក្នុងការធ្វើជាតំណាងឲ្យកូនក្តីជាច្រើនរបស់ខ្លួន ដោយមានធនធានសម្ភារ និង/ឬ ធនធានហិរញ្ញវត្ថុមានកម្រិតនោះ ទើបនៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងអស់នេះ ក៏ដូចជានៅក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនាពេលកន្លងមក អង្គបុរេជំនុំជម្រះបានចាត់វិធានការមួយចំនួនក្នុងការធានាថា មេធាវីតំណាងដើម

---

[១៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៧២ ដល់ ៧៣។

[១៥] សូមមើលផងដែរ បណ្តាឧទាហរណ៍នានាដែលបានដកស្រង់ក្នុងកថាខណ្ឌ ៧៣ នៃ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ។

បណ្តឹងរដ្ឋប្បវេណីបានទទួលគ្រប់លទ្ធភាពទាំងអស់ក្នុងការធ្វើជាតំណាងឱ្យកូនក្តីរបស់ខ្លួនឱ្យបានល្អជាទីបំផុត។ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យសហមេធាវីដាក់ព័ត៌មានបន្ថែម ជាមួយនឹងបណ្តឹងឧទ្ធរណ៍នេះ ដើម្បីគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់កូនក្តីខ្លួន ហើយអង្គជំនុំជម្រះក៏បានស្នើដល់សហមេធាវីមួយចំនួន ក្នុងករណីជាក់លាក់ខ្លះៗ ដើម្បីឱ្យសហមេធាវីដាក់ជូននូវព័ត៌មានបន្ថែម។ អង្គបុរេជំនុំជម្រះក៏បានទទួលយកផងដែរករណីដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ជូននូវព័ត៌មានបន្ថែម ជាទម្រង់នៃសេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយមេធាវី ប្រសិនបើមេធាវីបានបង្ហាញយ៉ាងច្បាស់ថា ខ្លួនបានទទួលព័ត៌មានទាំងនេះពីកូនក្តីរបស់ខ្លួន[១៦]។ ជាលទ្ធផល ម្ចាស់បណ្តឹងឧទ្ធរណ៍ចំនួន១.៧២៨ នាក់ ក្នុងចំណោម ១.៧៤៧ នាក់ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង០០២ ដោយសម្លេងគាំទ្រភាគច្រើនពីចៅក្រមអង្គបុរេជំនុំជម្រះ។ អង្គបុរេជំនុំជម្រះមិនបានដឹងអំពីករណីនៃការប្រព្រឹត្តខុសណាមួយដែលបានលើកឡើងប្រឆាំងនឹងសហមេធាវីដោយសារតែការរំលោភបំពានទៅលើកាតព្វកិច្ចរក្សាការសម្ងាត់របស់ខ្លួននោះឡើយ។ ចំពោះទឡ្ហីករណ៍ផ្សេងៗរបស់សហមេធាវីទាក់ទងដល់ការលំបាកនានាដែលខ្លួនអាចនឹងជួបប្រទះក្នុងពេលជំនុំជម្រះនោះ អង្គបុរេជំនុំជម្រះមិនមានយុត្តាធិការក្នុងការដោះស្រាយបញ្ហានេះឡើយ។

១២. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះមិនយល់ឃើញថា អង្គហេតុ និងកាលៈទេសៈក្នុងសំណុំរឿងបច្ចុប្បន្ននេះ តម្រូវឱ្យអង្គបុរេជំនុំជម្រះសម្រេចថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន ដោយការបកស្រាយទូលាយចំពោះវិធាន ២១ នៃវិធានផ្ទៃក្នុងនោះឡើយ។

---

[១៦] សូមមើលផងដែរ *ក្នុងចំណោមនោះ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ D404/2/4 និងD411/3/6 កថាខណ្ឌ ៥៥ និង យោបល់ជំទាស់ដោយឡែក និងមួយផ្នែក របស់លោកស្រីចៅក្រម CATHERINE Marchi-Uhel កថាខណ្ឌ ៦ កថាខណ្ឌ ២៣ និងកថាខណ្ឌ ៣៩។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទថា៖**

បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ។

ដោយអនុលោមទៅតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING នី យ ថុល Catherine MARCHI-UHEL ហ៊ុត វុទ្ធី ប្រាក់ គឹមសាន**